# ក្រុមមេធាវីការពារក្តីរបស់លោក អោ អាន
## AO An Defence Team

ថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០២០

**សូមគោរពជូន៖** លោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង
លោកចៅក្រម យ៉ា សុខន
លោកចៅក្រម យូ ឧត្តរា
លោកស្រីចៅក្រម Claudia FENZ
លោកចៅក្រម Martin KAROPKIN

**ចម្លងជូន៖** លោកស្រី ជា លាង សហព្រះរាជអាជ្ញាជាតិ
លោកស្រី Brenda HOLLIS សហព្រះរាជអាជ្ញាអន្តរជាតិ
សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤/២

**កម្មវត្ថុ៖** ***ចម្លើយតបទៅនឹងសំណើសាជាថ្មីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់វិធានការចាំបាច់ដើម្បីជំរុញសំណុំរឿង ០០៤/២ ទៅជំនុំជម្រះ រួមទាំងបង្គាប់ឱ្យមានការបញ្ជូនសំណុំរឿង ០០៤/២ ជាបន្ទាន់ទៅកាន់អង្គជំនុំជម្រះសាលាដំបូង***

### សូមគោរពជូន លោកប្រធាន និល ណុល និងលោក លោកស្រីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង

សហមេធាវីការពារក្តីរបស់លោក អោ អាន (បន្ទាប់ពីនេះហៅកាត់ថា "*សហមេធាវីការពារក្តី*") សូមគោរពដាក់ជូននូវចម្លើយតបទៅនឹង*សំណើសាជាថ្មីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់វិធានការចាំបាច់ដើម្បីជំរុញសំណុំរឿង ០០៤/២ ទៅជំនុំជម្រះ រួមទាំងបង្គាប់ឱ្យមានការបញ្ជូនសំណុំរឿង ០០៤/២ ជាបន្ទាន់ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង* ("*សំណើសុំសាជាថ្មីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ*")។[1] សហមេធាវីការពារក្តីសូមដាក់ចម្លើយតបនេះតាមរយៈលិខិតដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងមិនបានទទួលសំណុំរឿង ០០៤/២ ដោយស្របច្បាប់នោះទេ ហេតុដូច្នេះវាជាការមិនត្រឹមត្រូវក្នុងការដែលទំនាក់ទំនងជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងដោយអនុលោមតាមសេចក្តីណែនាំ

[1] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/អជសជ *សំណើសាជាថ្មីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់វិធានការចាំបាច់ដើម្បីជំរុញសំណុំរឿង ០០៤/២ ទៅជំនុំជម្រះរួមទាំងបង្គាប់ឱ្យមានការបញ្ជូនសំណុំរឿង ០០៤/២ ជាបន្ទាន់ទៅកាន់អង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០។

អនុវត្តសម្រាប់ការដាក់ឯកសារ។ មេធាវីការពារក្តីសូមបញ្ជាក់ដោយសេចក្តីគោរពថា អង្គជំនុំជម្រះសាលាដំបូងមិនមានយុត្តាធិការគ្រប់គ្រាន់ក្នុងការពិនិត្យទៅលើ*សំណើសុំសាជាថ្មីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ដោយស្របតាមមូលហេតុដូចខាងក្រោម៖

(១) ស្របតាមវិធាន ៦៩(២) នៃវិធានផ្ទៃក្នុង ការិយាល័យតុលាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលមានសិទ្ធិអំណាចចាំបាច់ជាផ្លូវការក្នុងការបញ្ជូនសំណុំរឿងនេះទៅអង្គជំនុំជម្រះសាលាដំបូង ឬនៅក្នុងករណីដែលលើកលែងការចោទប្រកាន់ ការបិទសំណុំរឿង និងរក្សាទុកក្នុងបណ្ណសារ គឺការិយាល័យសហចៅក្រមស៊ើបអង្កេត។ អង្គបុរេជំនុំជម្រះបានបញ្ជាក់ជាឯកឆ័ន្ទទៅលើគោលជំហរនេះផងដែរដោយបានលើកឡើងថា "*បានដាក់ទម្រង់បែបបទនៃការដាក់ឯកសារ និងការណែនាំអំពីការជូនដំណឹងភ្លាមៗក្រោយពីបានចេញសេចក្តីពិចារណា ដោយបានបង្គាប់ឱ្យអង្គភាពបណ្ណសារដាក់សេចក្តីពិចារណាជាសាធារណៈ និងជូនដំណឹងអំពីសេចក្តីពិចារណាទៅការិយាល័យសហចៅក្រមស៊ើបអង្កេត និងភាគីនៅក្នុងសំណុំរឿង ០០៤/២*"[2]

(២) នៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០២០ សហមេធាវីការពារក្តីបានដាក់ *សំណើសុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ*[3] ទៅការិយាល័យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុលោមតាមវិធាន ៦៩(២)(ខ) ដោយមានបញ្ជាក់ថា (i) អង្គបុរេជំនុំជម្រះខកខានក្នុងការដោះស្រាយលើការខ្វែងយោបល់គ្នាផ្ទៃក្នុង ហើយបច្ចុប្បន្នបានឈានដល់កម្រិតមួយនៃសិទ្ធិអំណាចក្នុងការសម្រេចលើលទ្ធផលនៃសំណុំរឿង០០៤/២[4] (ii) ការិយាល័យរដ្ឋបាលបានទទួលការណែនាំផ្ទុយគ្នាពីចៅក្រម ហើយមិនអាចចាត់វិធានការបានទេ[5] (iii) អង្គជំនុំជម្រះសាលាដំបូងដែលពុំទាន់បានទទួលរឿងក្តីនេះស្របតាមច្បាប់នៅឡើយ ហើយនៅពុំទាន់មានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ក៏ពុំអាច

---

[2] *អនុស្សរណៈអន្តរការិយាល័យចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ពាក់ព័ន្ធនឹងការផ្ទេរសំណុំរឿង ០០៤/២ ("អនុស្សរណៈចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០")*, កថាខណ្ឌ ២៧ មានភ្ជាប់ជាឧបសម្ព័ន្ធ ១។

[3] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស *សំណើសុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ* ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

[4] *អនុស្សរណៈចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០* កថាខណ្ឌ ២៧, ៣៣។

[5] *អនុស្សរណៈអន្តរការិយាល័យចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ សំណើសុំបញ្ជាក់បំភ្លឺអនុលោមតាមវិធាន ១០(២) ("អនុស្សរណៈចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០")* ត្រូវបញ្ជូនដោយ ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និង *Knut Rosandhaug* អនុប្រធានការិយាល័យរដ្ឋបាល កថាខណ្ឌ ១៣ ភ្ជាប់ជាឧបសម្ព័ន្ធ ២។

បំពេញកិច្ចបានដូចគ្នា[6] ហេតុដូច្នេះ (iv) ការិយាល័យសហចៅក្រមស៊ើបអង្កេត គឺជាអង្គភាពតុលាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតែមួយគត់ដែលទទួលអំណាចតាមវិធានផ្ទៃក្នុងអាចដោះស្រាយការជាប់គាំងនាពេលបច្ចុប្បន្ននេះ។ ចំពោះសំណើសុំនេះបច្ចុប្បន្នស្ថិតនៅក្នុងការរង់ចាំការសម្រេចនៅឡើយ។

(៣) អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមិនមានអំណាចតាមផ្លូវច្បាប់ក្នុងការធ្វើសកម្មភាព ឬសម្រេចលើបទបញ្ហាគតិយុត្តិណាមួយទាក់ទងនឹងសំណុំរឿង ០០៤/២ នោះទេ ខណៈពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានទទួលនូវ*សំណើសុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ*។ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានទទួលសេចក្តីចម្លងលើសំណើសុំនេះនៅថ្ងៃទី ២០ ខែមីនា ឆ្នាំ២០២០។[7] ប៉ុន្តែសហព្រះរាជអាជ្ញាអន្តរជាតិបានជ្រើសរើសនូវការមិនលើកឡើងថានៅមានសំណើសុំដែលកំពុងរង់ចាំសេចក្តីសម្រេចនេះ ទៅអង្គជំនុំជម្រះសាលាដំបូងនោះទេ។ ចំពោះសកម្មភាពនានា ឬសេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូងអាចនឹងដណ្តើមអំណាចស្របច្បាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត និងបំពានទៅនឹងវិធានផ្ទៃក្នុង។

(៤) បន្ថែមពីនេះទៀត មេធាវីការពារក្តីនៅតែជំទាស់ទៅលើជំហររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលលើកឡើងថាអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ០០៤/២ សម្រាប់មូលហេតុគឺសហមេធាវីការពារក្តីបានលើកឡើងនៅក្នុង "*សំណើរបស់អោ អាន សុំបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានទទួលលស្របច្បាប់នូវសំណុំរឿង ០០៤/២ និង សំណើសុំពន្យារពេល និងគោលការណ៍ណែនាំសម្រាប់ការដាក់អញ្ញត្រកម្មអនុលោមវិធាន ៨៩*"[8] និងដំណើរការនីតិវិធីជាបន្តបន្ទាប់នៅចំពោះមុខអង្គបុរេជំនុំជម្រះ។[9]

---

[6] *អ៊ីមែលពីក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគីពាក់ព័ន្ធនឹងសំណុំរឿង ០០៤/២* ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣។

[7] *អ៊ីមែលពីក្រុមមេធាវីការពារក្តី អោ អាន "ឯកសារចម្លងជូនអំពីសំណើសុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ (ជាឯកសារភាសាអង់គ្លេស)* នាថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០២០ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៤។

[8] ក្រុមមេធាវីការពារក្តី អោ អាន "*សំណើសុំបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានទទួលស្របច្បាប់នូវសំណុំរឿង ០០៤/២ និង សំណើសុំពន្យារពេល និងគោលការណ៍ណែនាំសម្រាប់ការដាក់អញ្ញត្រកម្មអនុលោមតាមវិធាន ៨៩* ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩។

[9] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០) *សំណើសុំការបញ្ជាក់ថាបានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ* ឯកសារ **D359/27 & D360/36** ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០២០។ សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ៦០) *ការឆ្លើយទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា*

យោងតាមការរៀបរាប់ខាងលើ មេធាវីការពារក្តីសូមបញ្ជាក់ដោយគោរពថាអង្គជំនុំជម្រះសាលាដំបូងមិនមានអំណាចផ្លូវច្បាប់ក្នុងការពិនិត្យទៅលើ*សំណើសុំសាជាថ្មីរបស់សហព្រះរាជអាជ្ញាអន្តរជាតិនោះទេ*។

ធ្វើនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា

សហមេធាវីការពារក្តីលោក អោ អាន

| | | |
|---|---|---|
| មុំ លុជ្ជ | Richard ROGERS | Goran SLUITER |

*អន្តរជាតិទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថាបានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ (“ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំរបស់ អោ អាន”)*
ឯកសារ **D359/31 & D360/40** ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។